មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វិចារណកថាព័ត៌មាន

*ភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២*

## សុន្ទរកថារបស់នាយករដ្ឋមន្ត្រីពាក់ព័ន្ធជម្លោះដីធ្លីគឺជាការបំពានច្បាប់ជាមូលដ្ឋាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋនៅខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២។ ថ្លែងទៅកាន់ក្រុមនិស្សិតជិតមួយពាន់នាក់ ប្រជាកសិករ និងមន្ត្រីរដ្ឋាភិបាលជាច្រើនទៀត លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានថា កុំឲ្យមានពាក់ព័ន្ធរឿងនយោបាយ ឬពង្រីករឿងឲ្យកាន់តែធំទៅលើបញ្ហាជម្លោះដីធ្លី។

យោងទៅតាមអត្ថបទក្នុងកាសែត ***ខេមបូឌាដេលី*** ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា "ខ្ញុំនឹងមិនដោះស្រាយ និងបង្អកទុកមួយកន្លែង (នូវជម្លោះដីធ្លី) ប្រសិនបើមានការពាក់ព័ន្ធពីអ្នកនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ឬគណបក្សនយោបាយ។" ពាក់ព័ន្ធនឹងសុន្ទរកថានេះ (ម.ស.ម.ក) យល់ឃើញថា វាគឺកាតព្វកិច្ចច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានាសិទ្ធិមានដីធ្លី និងលំនៅ-ឋានគ្រប់គ្រាន់របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើន ដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវមានកាតព្វកិច្ចលើកកំពស់ និងការពារសិទ្ធិមនុស្សទាំងអស់នេះ។ ក្នុងមាត្រា ២៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលបានទទួលស្គាល់ និងគោរពដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ ដែលក្នុងនោះបានចែងថា "មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខ-មាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ និងលំនៅឋាន។" បន្ថែមលើនោះទៀត នៅក្នុងមាត្រា ១១ នៃកតិកាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចែងអំពី "ការទទួលស្គាល់របស់ជនគ្រប់រូបក្នុងការទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ សម្រាប់ផ្ទាល់ខ្លួន និងសម្រាប់គ្រួសារខ្លួន រួមមានចំណីអាហារ សម្លៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់ ព្រមទាំងការរីកចម្រើនជាលំដាប់នៃល័ក្ខខ័ណ្ឌរស់នៅរបស់គេ។" និងបានចែងថា "រដ្ឋជាភាគីនឹងចាត់វិធានការសមស្របដើម្បីធានាធ្វើឲ្យបានសម្រេចនូវសិទ្ធិទាំងនេះ។"

ការបដិសេធដោះស្រាយជម្លោះដីធ្លីដែលមានពាក់ព័ន្ធពីអង្គកាមិនមែនរដ្ឋាភិបាល អ្នកនយោបាយ និងគណបក្សនយោបាយ គឺលោកនាយករដ្ឋមន្ត្រីកំពុងតែគំរាមដោយរំលោភទៅលើសិទ្ធិរបស់ប្រជាជនកម្ពុជា ដែលមានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ការព្រមានជនរងគ្រោះដោយសារការរំលោភដីធ្លីមិនអោយទាក់ទង

ជាមួយអង្គការមិនមែនរដ្ឋាភិបាល គឺរាជរដ្ឋាភិបាលកម្ពុជាកំពុងចាត់ទុកសង្គមស៊ីវិលជាបច្ចាមិត្រជាជាងភាពជាដៃ-គូ។ ម៉្យាងវិញទៀតក្នុងការព្រមានដោយនិយាយអំពីជម្លោះដីធ្លីនោះ លោកនាយករដ្ឋមន្ត្រីកំពុងតែបំពានទៅលើសិទ្ធជាមូលដ្ឋាននៃសេរីភាពក្នុងការបញ្ចេញមតិដែលការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ដោយសារតែរដ្ឋាភិបាលមានភាពអាក់អួល ក្នុងការបំពេញតួនាទីរបស់ខ្លួន ដើម្បីដោះស្រាយជម្លោះដីធ្លី អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ការគាំទ្រដល់ជនរងគ្រោះតាមរយៈ បើកវគ្គបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស និងការតស៊ូមតិ ផ្តល់ជំនួយផ្នែកមនុស្សធម៌និងជួយជនរងគ្រោះទាំងនោះក្នុងការសរសេរនិងដាក់ពាក្យបណ្តឹង។ ការព្យាយាមបំបែកជនរងគ្រោះពីអង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយនាពេលនេះ បណ្តាលអោយស្ថាន-ភាពសិទ្ធិមនុស្សកាន់តែមានសភាពធ្ងន់ធ្ងរទៅ។

លោក វណ្ណ សុផាត មន្ត្រីសម្របសម្រួលកម្មវិធីកំណែទម្រង់ដីធ្លីនៃ(ម.ស.ម.ក) បានមានមតិថា៖ "សុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រីបានបង្ហាញយ៉ាងច្បាស់អំពីចេតនាក្តោបអំណាចនៅក្នុងប្រទេសកម្ពុជា។ សារនេះបានរំលេចនូវការបន្តរឹតបន្តឹងលើសិទ្ធិមនុស្សនិងសេរីភាពរបស់ជនរងគ្រោះដោយសារជម្លោះដីធ្លី ហើយក៏បានបង្ហាញអំពីសេចក្តីប្រាថ្នារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការត្រួតត្រាអង្គការមិនមែនរដ្ឋាភិបាល និងគាបសង្កត់គណបក្សប្រឆាំង។" លោក វណ្ណ សុផាត បានបន្ថែមទៀតថា "ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងដែលជនរងគ្រោះដោយសារជម្លោះដីធ្លីត្រូវបានប្រើប្រាស់ជាចំណាប់ខ្មាំងនយោបាយនៅក្នុងប្រទេសកម្ពុជា។ សាររបស់លោកនាយករដ្ឋមន្ត្រីបានធ្វើអោយមានភាពមន្ទិល ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ចំពោះគោលនយោបាយដីធ្លីរបស់គណបក្សប្រជាជនកម្ពុជា ជាពិសសនៅក្នុងការប្រកួតប្រជែងបោះឆ្នោតជាទូទៅនៅក្នុងឆ្នាំ ២០១៣ ខាងមុខនេះ។"

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក វណ្ណ សុផាត មន្ត្រីសម្របសម្រួលកម្មវិធី កំណែទម្រង់ដីធ្លី (+៨៥៥ (0) ១២ ៩៤១ ២០៦ ឬអ៊ីម៉ែល៖ vann.sophath@cchrcambodia.org ឬ លោក អ៊ូ វិរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (+៨៥៥ (0) ១២ ៤០៤ ០៥១ ឬអ៊ីម៉ែល៖ ouvirak@cchrcambodia .org ។**

ព័ត៌មានបណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិ ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងនយោបាយនៅកម្ពុជា ។

ម.ស.ម.ក គឺជាសមាជិកដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) បណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលរង្វាន់មូលនិធិនៃការបង្កើត សង្គមព័ត៌មានថ្មីប្រចាំឆ្នាំ ២០១២ ស្ថិតនៅក្នុងប្រភេទ "សិទ្ធិ និង សេរីភាព"។